**កិច្ចប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០១៦**
**សម្រាប់**
**កម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម (EIF) ជំហ៊ានទី ១ និង ជំហ៊ានទី ២ នៃកម្មវិធី CEDEP I និង CEDEP II**
**ភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦**
**<u>គោលបំណង និងចំណុចគន្លឹះសំខាន់ៗនៃកិច្ចប្រជុំ</u>**

## ១ . សាវតា

កិច្ចប្រជុំប្រចាំត្រីមាសត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងផែនការសកម្មភាពប្រចាំឆ្នាំ ២០១៦ នៃកម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម (EIF) ជំហ៊ានទី ១ និង ជំហ៊ានទី ២ នៃកម្មវិធី CEDEP I និង CEDEP II។

## ២.គោលបំណងនៃកិច្ចប្រជុំ

គោលបំណងរួមនៃកិច្ចប្រជុំប្រចាំត្រីមាសគឺដើម្បីៈ

- ☞ ផ្តល់ព័ត៌មានពីការវិវឌ្ឍន៍ថ្មីៗនៃកម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម (EIF) ក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ។
- ☞ ធ្វើបច្ចុប្បន្នភាពពីវឌ្ឍនភាពការងារដែលអនុវត្តន៍ដោយភ្នាក់ងារអនុវត្តគម្រោង MIEs
- ☞ ពង្រឹង និងលើកកម្ពស់កិច្ចសហប្រតិបត្តិការអនុវត្តន៍គម្រោងរវាង DICO, MIEs, និងក្រសួងស្ថាប័នពាក់ព័ន្ធ។
- ☞ ផ្សព្វផ្សាយ និងចែករំលែកព័ត៌មាន, បទពិសោធន៍ និងមេរៀនដែលទទួលបានពីការអនុវត្តគម្រោងដល់ភាគីពាក់ព័ន្ធ, និង
- ☞ ពិនិត្យមើលបញ្ហាប្រឈម និងស្វែងរកដំណោះស្រាយ។

**ចំណុចគន្លឹះសំខាន់ៗៈ**

- ☞ ត្រៀមរៀបចំទទួលគណៈប្រតិភូពីសាកលវិទ្យាល័យកូរ៉េខាងត្បូង សាលាក្រោយឧត្តមសិក្សាអន្តរជាតិ (GSIS) មកសិក្សាស្វែងយល់ពីការគ្រប់គ្រងជំនួយសម្រាប់ពាណិជ្ជកម្ម (AfT), កម្មវិធី EIF/TDSP និង Trade SWAp កម្ពុជា នៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦។
- ☞ ការរៀបចំទទួលដំណើរបេសកកម្មត្រួតពិនិត្យការអនុវត្តន៍កម្មវិធី EIF Tier 1 និង Tier 2-EDEP I & II ពីលេខាធិការដ្ឋាន EIF និងអង្គការ UNOPS Trust Fund ចាប់ពីថ្ងៃទី១៥-១៧ ខែកុម្ភៈ ឆ្នាំ២០១៦។
- ☞ ការវាយតម្លៃពាក់កណ្តាលគម្រោងនៃកម្មវិធី CEDEP II (Mid-term Evaluation – CEDEP II) ។
- ☞ ការវាយតម្លៃបញ្ចប់កម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម ជំហានទី១ ( Final Evaluation of EIF Tier 1) និងការបិទកម្មវិធី EIF Tier 1 កម្ពុជា នៅថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៦។
- ☞ ការរៀបចំឯកសារទស្សនាទានចំនួន៥ ផ្សេងទៀត (Other five project concept notes) សម្រាប់ស្វែងរកជំនួយបច្ចេកទេសពាណិជ្ជកម្ម ២០១៦-២០២០។
- ☞ ការរៀបចំកិច្ចពិភាក្សាតុមូល រវាងក្រសួងពាណិជ្ជកម្ម និងដៃគូរអភិវឌ្ឍន៍ ស្តីពីជំនួយសម្រាប់ពាណិជ្ជកម្ម ២០១៦-២០២០ (MoC-DP roundtable discussion on AFT 2016-2020)។

**របៀបវារៈ**

១. ធ្វើបច្ចុប្បន្នពីសន្និសិទស្វែងរកការគាំទ្រពីម្ចាស់ជំនួយនៃកម្មវិធី EIF សម្រាប់ដំណាក់កាលទី២, ការរៀបចំសំណើគម្រោងសម្រាប់ CEDEP III និង កិច្ចពិភាក្សាតុមូល រវាងក្រសួងពាណិជ្ជកម្ម និងដៃគូរអភិវឌ្ឍន៍ ស្តីពីជំនួយសម្រាប់ពាណិជ្ជកម្ម ២០១៦-២០២០។

២. ផែនការសកម្មភាពសំខាន់របស់កម្មវិធី EIF នៅកម្ពុជា។

៣.ធ្វើបច្ចុប្បន្នភាពពីវឌ្ឍនភាពការងារដោយភ្នាក់ងារអនុវត្តន៍គម្រោង, បញ្ហាប្រឈម និងដំណោះស្រាយ។

៤. ការពិភាក្សាជារួមលើការងារអនុវត្តន៍គម្រោង

---